ព្រះមហាវីរិយបណ្ឌិតោ **ប៉ាង ខាត់**

# ឧបនីយតិសូត្រ



ព.ស. ២៤៨៣ - គ.ស. ១៩៤០

* ចម្លងតាមច្បាប់ដើម

ព.ស. ២៥៥៦ - គ.ស. ២០១២

**សម្រាប់ចែកជាធម្មទាន**

# ឧបនីយតិសូត្រ

គឺ

ព្រះមហា **ប៉ាង ខាត់** វីរិយបណ្ឌិតោ

ក្រុមជំនុំប្រែព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

*រៀបរៀង*

ព្រះពោធិវង្ស **ហ. តាត**

ចាងហ្វាងសាលាបាលីជាន់ខ្ពស់

បានពិនិត្យផ្ទៀងផ្ទាត់

គណៈរដ្ឋមន្ត្រី និង សម្តេចព្រះសង្ឃនាយកទាំងពីរគណៈ

បានយល់ព្រមហើយ

**ព.ស. ២៤៨៣ - គ.ស. ១៩៤០**

(រូបក្របខាងមុខ: ព្រះពុទ្ធប្បដិមា នៅភ្នំសន្ទុក ខេត្តកំពង់ធំ)

*ចម្លងតាមច្បាប់ដើមដោយខ្ញុំព្រះករុណា ខ្ញុំបាទ **វ៉ាត តិរក្ស**

**ព.ស. ២៥៥៥ - គ.ស. ២០១២**

**សំរាប់ជាធម្មទាន**

# សៀវភៅចាស់ដែលបានចម្លងជាថ្មី ៖

១. ស្នាព្រះហស្តក្រោយបង្អស់នៃសម្តេចព្រះមហាសុមេធាធិបតី **ជួន ណាត**

២. ធម៌នមស្ការព្រះរតនត្រ័យ ពិស្តារ - សង្ខេប

៣. ប្រស្នា គិហិប្រតិបត្តិពិស្តារ ( ឈឹម ទូច, សុង ស៊ីវ )

៤. ប្រជុំនានាធម៌សង្វេគ ( ជ័យ ម៉ៃ )

៥. អានាបាណស្សតិកម្មដ្ឋាន វិបស្សនាបញ្ហាធម្មបរិយាយ ( គង់ ឌឹប )

៦. ធម្មនិយាម ៣០ និងកំណាព្យផ្សេង ៗ ( ប៊ុត សាវង្ស, សាន សុជា )

៧. ជីវិតកថា ( ម៉ិញ សាវ៉ាន )

៨. ធម្មប្រទីប ( ប្រជុំកងធម៌ យិន វន់ )

៩. រឿង ព្រះភិក្ខុពនេចរ ( ឱម ណាគ្រី )

១០. រឿង នគរកាយ ( ចាប ពិន )

១១. ច្បាប់គោរពមាតាបិតា ( អ៊ូ ចុង )

១២. នត្ថិធម្មាធិប្បាយ ( ព្រះបិដកធម្ម អ៊ុម ស៊ុម )

១៣. ត្រៃកូដធម៌ ( សុង ស៊ីវ )

១៤. ឱវាទបាតិមោក្ខ ( ចាប ពិន )

១៥. កម្រងកំណាព្យ ( ហ៊ុម ឆាន់ )

# ឧទ្ទិសកថា

**យើង**ខ្ញុំ សូមលើកយកនូវផលានិសង្សដែលកើតឡើងអំពីអាមិសទាននិងធម្មទាននេះ ឧទ្ទិសជូនដល់ លោក-អ្នកដ៏មានគុណទាំងឡាយមាន ជីដូនជីតា, មាតាបិតា, គ្រូឧបជ្ឈាយាចារ្យ, ញាតិកា, លោកអ្នកប្រាជ្ញ-កវី ជាបុព្វការីជនទាំងអស់ ដែលបានចែកស្ថានទៅកាន់បរលោកក្តី រស់នៅក្តី សូមលោកទាំងនោះបានទទួលនូវឥដ្ឋមនុញ្ញផលរៀងៗខ្លួន តទៅកុំបីអាក់ខានឡើយ ។

**ក៏**សូម ឧទ្ទិសនូវផលានិសង្សនេះដែរជូនដល់ពុទ្ធបរិស័ទដែលជាសទ្ធាសម្បន្ន និងសទ្ធាសម្បន្នាចិត្តបុណ្យទាំងអស់ សូមបាននូវសម្មាទិដ្ឋិគ្រប់ៗជាតិ និងបាននូវឧបនិស្ស័យរួចផុតចាកទុក្ខកុំបីឃ្លៀង-ឃ្លាតឡើយ ហើយសូមឲ្យមានប្រាជ្ញាថ្លាគំនិត បដិបត្តិព្រះធម៌បានសម្រេចមគ្គផលសមតាមសេចក្តីប្រាថ្នារបស់អស់លោក-អ្នកទាំងឡាយកុំបីឃ្លាតក្លាយទៅជាបការៈដទៃឡើយ ។

**សូមអនុមោទនា !!!**



សូមឧទ្ទិសកុសលនៃ " **ធម្មទាន** " នេះ

ជូនចំពោះ

ឧបាសិកា **ជា យន**

**១៩២២ - ២០០៨**

# ខួបលើកទី ៤

# ពាក្យប្រារព្ធ

សៀវភៅ " **ឧបនីយតិស្សូត្រ** " ដែលរៀបរៀងដោយព្រះមហាវីរិយបណ្ឌិតោ **ប៉ាង ខាត់** បើគិតទៅព្រះធម៌នេះមានអាយុ ៧២ ឆ្នាំហើយមកទល់នឹងឆ្នាំនេះ ។

ដោយធ្លាប់មានពុទ្ធបរិស័ទគ្រប់ជំនាន់ មានការពេញចិត្តចំពោះព្រះធម៌នេះ, ខ្ញុំព្រះករុណា ខ្ញុំបាទក៏មានសទ្ធាជ្រះថ្លាយកសៀវភៅនេះមកចម្លងធ្វើជាសៀវភៅថ្មី សំរាប់ចែកជូនជាធម្មទាននៅក្នុង ឱកាសបុណ្យទក្ខិណានុប្បទាន " ឆ្នាំទី ៤ " របស់ឧបាសិកា **ជា យន** ជាម្តាយនៅក្នុងខែជេស្ឋ ព.ស. ២៥៥៦ ត្រូវនឹងខែមិថុនាឆ្នាំ ២០១២ ។

ខ្ញុំព្រះករុណា សូមលើកហត្ថទាំងទ្វេ លំអោនកាយ វាចា ចិត្តគោរពដល់ព្រះអង្គដែល ជាអ្នកប្រាជ្ញ, ជាបណ្ឌិត ដែលជាម្ចាស់សៀវភៅនេះសូមលោកអនុញ្ញាតដល់ខ្ញុំព្រះករុណា ដើម្បីសរសេរចម្លង និង រៀបរៀងឡើងវិញនូវសៀវភៅ **ឧបនីយតិស្សូត្រ** របស់លោកសាជាថ្មីឡើងវិញ ។

ខ្ញុំសូមថ្លែងអំណរគុណដល់ ៖

- ឧបាសក **មុិញ សាវ៉ាន** និងឧបាសក **ហ៊ុម ឆាន់** លោកជាព្រឹទ្ធាចារ្យរបស់ខ្ញុំ ដែលតែងតែផ្តល់នូវគតិយោបល់ល្អៗ ចំណាយពេលវេលាពិគ្រោះទាំងខាងផ្លូវលោកនិងផ្លូវធម៌ ហើយជួយត្រួតពិនិត្យកែសំរួលពាក្យពេចន៍អក្ខរាវិរុទ្ធ ដើម្បីធ្វើឲ្យសៀវភៅនេះបានល្អ និងត្រឹមត្រូវមិនឲ្យឃ្លៀងឃ្លាតពីច្បាប់ដើម ។

សូមអភ័យទោសចំពោះកំហុសឆ្គាំឆ្គងគ្រប់យ៉ាង ព្រោះកំហុសមានច្រើន ជួនខុសដោយអចេតនា ជួនខុសដោយផ្ទៀងផ្ទាត់មិនបានជិតដល់ និង ជាពិសេសខុសដោយខ្ញុំព្រះករុណា ខ្ញុំបាទមានការចេះដឹងតិចតួចស្តួចស្តើងពេក ក៏ប៉ុន្តែ ខ្ញុំព្រះករុណា ខ្ញុំបាទ គ្មានចេតនារម្មណ៍នឹង

ក្លែង ពោល មួល ព្រះពុទ្ធដីកាសោះឡើយ គឺចង់ថែរក្សាទុកសម្រាប់ជាអាយុនៃព្រះពុទ្ធសាសនា ទៅក្នុងអនាគតតែប៉ុណ្ណោះ ។

ទូលព្រះបង្គំ ខ្ញុំព្រះករុណា សូមឧទ្ទិសបុណ្យ ដែលកើតឡើងអំពីសេចក្ដីព្យាយាម ធ្វើជាសៀវភៅថ្មីនេះ ថ្វាយ ប្រគេនដល់ ៖

- សម្ដេចព្រះសង្ឃរាជ **ជួន ណាត** ជោតញ្ញាណោ
  **ប.អ.ស - អ.ម.រ**(១)
- ព្រះមហាវីរិយបណ្ឌិតោ **ប៉ាង ខាត់**
- ព្រះពោធិវង្ស **ហួត តាត**

សូមព្រះអង្គទទួលអនុមោទនា នូវកុសលផលបុណ្យនៃធម្មទាននេះ ដោយព្រះទ័យជ្រះថ្លា ។

ក៏សូមឲ្យលោកអ្នកប្រាជ្ញ បណ្ឌិត ទាំងអស់ ព្រមទាំងសព្វសត្វក្នុងត្រៃភព បាននូវចំណែកបុណ្យនេះ និងបានសម្រេចនូវសេចក្ដីសុខគ្រប់ប្រការ ។

**សូមអនុមោទនា** !!!

ក្រុងម៉ុងរេអោល, ថ្ងៃ ១ ៨ ៦ ឆ្នាំរោង ចត្វាស័ក ព.ស. ២៥៥៦(២)
ត្រូវនឹងថ្ងៃអាទិត្យ ទី ១៣ ខែឧសភា គ.ស. ២០១២

**អ្នកសរសេរចម្លង**
**វ៉ាត តិរក្ស**

---

(១) អានថា បណ្ឌិតអក្សរសាស្ត្រ - អភិធជមហារដ្ឋគុរុ (អ:ភិធ:ជ: ម:ហារ័ត-ប:គុរុ)

(២) អានថា ថ្ងៃអាទិត្យ ៨រោច ខែពិសាខ ឆ្នាំរោង ចត្វាស័ក ព.ស. ២៥៥៦

# សេចក្តីយល់ព្រម

*សៀវភៅឧបនីយតិសូត្រនេះ ខ្ញុំបានឲ្យលោកអាចារ្យ* **ប៉ាង ខាត់** *រៀបរៀង ហើយបានសុំអនុញ្ញាតបោះពុម្ព ចែកដល់ពួកពុទ្ធបរិស័ទជាធម្មទាន ក្នុងឱកាសបុណ្យចំរើនជន្មាយុព្រោមរបស់ខ្ញុំ នៅវត្តប្រាង្គ-ឧដុង្គ នាថ្ងៃសុក្រ - សៅរ៍ អាទិត្យ - ច័ន្ទ ៧ - ៨ - ៩ - ១០ កើត ខែមិគសិរ ឆ្នាំរោងទោស័ក ព.ស.២៤៨៣ គឺថ្ងៃទី ៦ - ៧ - ៨ - ៩ ខែធ្នូ ឆ្នាំ ១៩៤០ ម្តងរួចហើយ ។*

*តមក មានបព្វជិតនិងគ្រហស្ថជាច្រើន ចង់បានសៀវ - ភៅនេះយកទៅសិក្សារៀនសូត្រ បានទៅសួររករោងពុម្ពខេមរដ្ឋជារឿយៗ ទើបរោងពុម្ពបានសុំសៀវភៅនេះអំពីខ្ញុំយកទៅបោះពុម្ពទុកបម្រុងដល់អ្នកដែលត្រូវការជាវយកទៅរៀនសូត្រ ឲ្យសម្រេចតាមបំណង ។*

*ខ្ញុំក៏បានយល់ព្រមអនុញ្ញាតឲ្យរោងពុម្ពខេមរដ្ឋ បោះពុម្ពសៀវភៅនេះតាមសេចក្តីត្រូវការ ដោយសង្ឃឹមថានឹងបានជាអាយុនៃព្រះពុទ្ធសាសនា ទៅក្នុងអនាគត ។*

**ព.ស.២៤៩៣ ថ្ងៃទី២៥ ខែសីហា ឆ្នាំ ១៩៥០**

*ព្រះពោធិវង្ស*

**ហួត តាត**

## នមត្ថុ រតនត្តយស្ស

# ឧបនីយតិសូត្រ

**ឧបនីយតិ ជីវិតប្បមាយុំ**
**ជរូបនីតស្ស ន សន្តិ តាណា**
**ឯតំ ភយំ មរណោ បេក្ខមានា**
**បុញ្ញានិ កយិរាថ សុខាវហានិ**

ប្រែ " **អាយុគឺជីវិត (នៃសត្វទាំងឡាយ) មានប្រមាណតិច ដ្បិតត្រូវជរានាំចូលទៅ ( កាន់សេចក្តីស្លាប់ ) សត្វដែលត្រូវជរានាំចូលទៅ ( កាន់សេចក្តីស្លាប់ ) ហើយ ឥតមានអ្វីជាទីពឹងពំនាក់ឡើយ : បុគ្គលកាលឃើញភ័យក្នុងសេចក្តីស្លាប់ គប្បីធ្វើបុណ្យ ជាគ្រឿងនាំសេចក្តីសុខមកប្រគល់ឲ្យ** " ។

លំដាប់តទៅ, សូមអធិប្បាយសេចក្តីតាមន័យ ក្នុងព្រះគាថាដែលបានប្រែជាសេចក្តីខាងលើនេះ សម្រាប់ជាផ្លូវប្រតិបត្តិនៃពុទ្ធសាសនិកជនទាំងឡាយ ដែលស្រឡាញ់ព្រះពុទ្ធសាសនាស្មើជីវិត ។ តែមុននឹងអធិប្បាយសេចក្តី

ឲ្យងាយស្តាប់ចូលចិត្តបាននុ៎ះ សូមប្រមូលផ្តែសេចក្តីក្នុងព្រះគាថានេះទុកជាគោលសិន ល្មមអស់លោក-អ្នកទាំង-ឡាយ ជាធម្មកាមបុគ្គល អាចកំណត់ចាំទុកក្នុងចិត្តបាន សឹមអធិប្បាយពង្រីកសេចក្តីទៅតាមទំនងធម៌ ទុកជាសណ្តាប់អស់លោក-អ្នកដែលពុំទាន់បានសិក្សាជ្រាលជ្រៅក្នុងផ្លូវព្រះពុទ្ធសាសនា ។

ឯគោលសេចក្តីក្នុងបាទបទព្រះគាថានេះ បើរួមជាបទមាតិកាមាន ៥ ប្រការគឺ ៖

**១. អាយុ គឺជីវិតនៃសត្វមានប្រមាណតិច;**

**២. មានជរាជាធម្មតា;**

**៣. មិនមានអ្វីជាទីពឹងជួយការពារបាន;**

**៤. សេចក្តីស្លាប់ជាភ័យនៃសត្វលោក;**

**៥. ការបំពេញបុណ្យជាគ្រឿងនាំសេចក្តីសុខមកឲ្យ;**

បទទី ១ និងបទទី ២ ទ្រង់រំឭកដាស់តឿនមិនឲ្យសត្វលោកស្រវឹងក្នុងជីវិត ក្នុងទ្រព្យសម្បត្តិ ហើយភាន់ច្រឡំយល់ថាជារបស់ខ្លួនពិតប្រាកដ ។ ទ្រង់សំដែងពន្យល់ឲ្យដឹងច្បាស់ថា ទ្រព្យសម្បត្តិអស់នេះ នឹងវិនាសព្រាត់ប្រាសចាកចោលយើងទៅ ឬយើងត្រូវព្រាត់ប្រាសចាកចោល

ទ្រព្យសម្បត្តិទៅមិនខាន ។ សូម្បីសត្វលោកក្នុងត្រៃភព ក៏ត្រូវវិនាសព្រាត់ប្រាសដូចគ្នាទាំងអស់ដែរ ព្រោះការព្រាត់ប្រាសចាកសត្វនិងសង្ខារនេះជាធម៌សម្រាប់ជនទូទៅ ។

បទទី ៣ ទ្រង់រំឭកដាស់តឿនឲ្យសត្វលោកស្វែងរកទីពឹងរបស់ខ្លួន គឺថាត្រូវធ្វើខ្លួនឲ្យជាទីពឹងរបស់ខ្លួន ធ្វើខ្លួនឲ្យមានខ្លឹមសារ ដោយការដឹងច្បាស់នូវសភាវធម៌ដែលតែងមានជាធម្មតា ។ មិនគួររីករាយសប្បាយហួសហេតុក្នុងពេលដែលបានទទួលអារម្មណ៍សមតាមប្រាថ្នា ទាំងមិនគួរឲ្យមានទោមនស្សតូចចិត្ត ក្នុងពេលដែលមិនបានទទួលអារម្មណ៍សមតាមប្រាថ្នាឡើយ ។

បទទី ៤ ទ្រង់សំដែងប្រាប់ថា សេចក្តីស្លាប់ជាភ័យធំនៃសត្វលោក ព្រោះថាសត្វលោកត្រូវស្លាប់គ្រប់គ្នា គេចរត់ទៅណាមិនរួចឡើយ ។

បទទី ៥ ទ្រង់សំដែងពន្យល់ថា កាលបើគេចមិនរួចពីសេចក្តីស្លាប់ដូច្នេះហើយ បើចង់បានសេចក្តីសុខ ត្រូវខំកសាងបំពេញសេចក្តីល្អគឺបុណ្យ ( ឲ្យច្រើនៗ ) ។ ពុទ្ធសាសនិកជនទាំងឡាយ គួរពិនិត្យសង្កេតសេចក្តីនេះឲ្យយល់ច្បាស់លាស់ទើបនឹងមានសន្តានចិត្តរីករាយសប្បាយ

មិនក្តៅក្រហាយ រោលរាល ដោយភ្លើងទុក្ខភ្លើងកិលេសឡើយ ។ កាលបើបានជួបប្រទះ នឹងសេចក្តីប្រែប្រួលនៃសភាវធម៌ ដែលតែងមានជាធម្មតា; អស់លោក-អ្នកទាំង-ឡាយក៏មិនកើតសេចក្តីក្តៅក្រហាយ តែងសម្រេចឥរិយា-បថទាំង ៤ ជាសុខទៅបាន ។

សូមលើកបទមួយៗ ដែលបានរួបរួមទុកជាបទមាតិកាខាងដើម យកមកអធិប្បាយស្រាយជាសេចក្តីមួយម្តងៗ ទុកជាប្រដាប់ប្រាជ្ញាបារមីរបស់អស់លោក-អ្នកជាធម្មកាមបុគ្គលទាំងឡាយ ដូចសេចក្តីតទៅនេះ ៖

## ១. អាយុ គឺជីវិតនៃសត្វមានប្រមាណតិច

ជីវិត គឺសេចក្តីរស់នៅរបស់មនុស្សយើងនេះ អ្នកដែលសម្បូរដោយការត្រិះរិះពិចារណាឃើញ ថាប្លែកអស្ចារ្យណាស់ តែអ្នកដែលមិនបានគិតពិចារណា ក៏ឥតយល់ថាដូចម្តេចឡើយ ។ ផលនៃមនុស្សទាំងពីរផ្នែកនេះកើតឡើងខុសគ្នា អ្នកដែលឧស្សាហ៍រៀនឲ្យចេះដឹងរឿងរ៉ាវនៃជីវិត ក៏អាចឆ្លៀវឆ្លាសស្គាល់ដល់សភាវធម៌ដ៏ពិតតែងស្ងប់ស្ងាត់ ត្រជាក់ចិត្តមិនរងទុក្ខវេទនាក្នុងកាលដែលសភាវធម៌ប្រែប្រួលទៅតាមធម្មតា ។ ចំណែកអ្នកមិនបានឧស្សាហ៍

ត្រិះរិះ រៀនឲ្យចេះដឹងសភាវធម៌នេះទេ តែងបានសេចក្តីវេទុក្ខវេទនា ក្រវល់ក្រវាយយ៉ាងខ្លាំងលើសប្រក្រតីព្រោះមិនដឹងមិនស្គាល់សភាវធម៌ ដែលត្រូវតែប្រែប្រួលទៅតាមធម្មតា ទើបបានទទួលសេចក្តីទុក្ខលំបាកគ្រប់ប្រការ ។

ហេតុនេះ ពាក្យថា "**ជីវិត**" នេះជាតួប្រស្នាមួយ គួរគិតណាស់ គួរយើងសួរខ្លួនយើងថា " **ជីវិតគឺអ្វី?** " ។ សូមអស់លោក-អ្នកទាំងឡាយ គិតពិចារណាមើលថាដូចម្តេចបានជាយើងរាល់គ្នាកើតមកហើយមាន ជរា ចាស់គ្រាំគ្រា, ឈឺទុរន់ទុរា, ស្លាប់ បានទទួលសេចក្តីក្តៅក្រហល់ក្រហាយ ក្រវល់ក្រវាយច្រើនប្រការម្ល៉េះ? ក្នុងពេលដែលយើងមានជីវិតរស់នៅនេះ ដូចម្តេចក៏មានមនុស្សខ្លះលោភ, ខ្លះមានសេចក្តីក្រោធ មានសេចក្តីវង្វេង ភាន់ច្រឡំមិនស្គាល់ខុសត្រូវ? មនុស្សខ្លះល្អមិនសូវលោភលន់ពន់ប្រមាណ? មិនសូវក្រេវក្រោធ មិនសូវវង្វេងឈ្លក់ជ្រុល ជាទំនាស់នឹងគ្នាដូច្នេះ? ព្រះពុទ្ធសាសនាមានគោលសំខាន់ថា ៖ **អំពើគ្រប់យ៉ាងសុទ្ធតែមានហេតុ បើហេតុមិនមាន ផលក៏មិនមាន, បើហេតុល្អ ផលក៏ល្អ, ហេតុអាក្រក់ផលក៏អាក្រក់** ។ នេះជាគោលសំខាន់ ដែលគេនាំយកទៅ

ប្រើទូទៅមិនថាប្រស្នាអ្វីឡើយ ។ ក្នុងថ្ងៃមួយៗនៃជីវិត, បើយើងកើតក្តៅក្រហាយមិនសប្បាយចិត្ត ត្រូវស្រាវជ្រាវរកហេតុថា សេចក្តីក្តៅក្រហាយនេះកើតមកពីណា? អ្វីធ្វើឲ្យកើតឡើង? ។ បើបានគិតពិចារណាដោយវិចារណ-ញ្ញាណ ដ៏សុខុមល្អិត ហើយយើងក៏អាចដឹងបានថា កើតមកពីហេតុនោះៗ, បើយើងរកហេតុឃើញហើយ យើងឃើញផល, បើហេតុរលត់ ផលក៏រលត់ទៅដូចគ្នា ។ ប្រស្នារឿងជីវិតនេះ កើតឡើងជាចំណោទនៃចិត្តទាំង-ឡាយរាល់ថ្ងៃ គិតពិចារណារាល់ថ្ងៃទៅ គិតច្រើនឡើងទៅក៏ចេះដឹងរឹតតែច្រើនឡើង រហូតដល់អាចចូលចិត្តសេចក្តីយ៉ាងសុខុមថា ជីវិតគឺសេចក្តីរស់នៅនៃយើងគឺអ្វី? បើនិយាយតាមគោលព្រះពុទ្ធសាសនា ជីវិតនេះក៏គឺសេចក្តីរស់នៅ ដែលកើតមកអំពីគ្រឿងប្រុង នៃសភាវធម៌ផ្សេងៗ មានហេតុមានបច្ច័យជាគ្រឿងទំនុកបម្រុងឲ្យកើតដែលនឹងបែកធ្លាយទៅវិញក៏ព្រោះអស់ហេតុ អស់បច្ច័យជាគ្រឿងប្រុងដូចគ្នា ។ ចូរពិនិត្យមើលរូបរាងកាយខាងក្រៅនៃយើងគ្រប់គ្នា ដែលកើតមកអំពីចំណែកគ្រឿងផ្សំមានធាតុទាំង ៤ គឺ ៖ ដី, ទឹក, ភ្លើង, ខ្យល់ ជាមេតាំងដំបូង អាស្រ័យការជាប់ទាក់ទងគ្នានៃហេតុផ្សេងៗ ទើប

អាចទ្រទ្រង់ស្ថិតនៅបាន ដូចអាហារ ទឹក អាកាស សុទ្ធតែជាគ្រឿងប្រុងតុបតែងដូចគ្នា បើខ្វះខាតធាតុណាមួយក៏រលត់រលាយទៅ ដល់ទីបំផុតក៏ត្រូវរលត់ផុតចេញពីគ្នា ចូលមកត្រូវគ្នានឹងគោលព្រះពុទ្ធសាសនាថា ៖ " **របស់ណាដែលកើតឡើងហើយ របស់នោះក៏ត្រូវរលត់ទៅវិញជាធម្មតា ( មិនស្ថិតស្ថេរទៀងទាត់ជាប់លាប់តាំងនៅក្រោមបង្គាប់អ្នកណាឡើយ)"** សូម្បីនាមធម៌ ក៏ត្រូវវិលប្រព្រឹត្តទៅតាមអំណាចរបស់អវិជ្ជា, តណ្ហា, ឧបាទាន, កម្មដែលជាហេតុនៃការវិលវល់ទៅកាន់សេចក្តីទុក្ខ ក្តៅក្រហាយ ។ ឯការដែលប្រព្រឹត្តប្រែប្រួលទៅតាមធម្មតាដូច្នេះ នាំឲ្យយើងដឹងច្បាស់ថាជីវិតនេះកើតមកអំពីរបស់ផ្សំគ្នា គឺថាបើធាតុទាំង ៤ មកចួបគ្នា រួមផ្សំគ្នាឲ្យកើតជារូបមួយកាលណា ជីវិតគឺការរស់នៅក៏កើតឡើងអាស្រ័យនឹងធាតុទាំង ៤ ផ្សំគ្នាក្នុងកាលនោះ ។ ហេតុនោះ ធម្មជាតិឯណាជារបស់ផ្សំ ធម្មជាតិនោះក៏សុទ្ធតែមិនថាវរៈមាំមួនទាំងអស់ ព្រោះត្រូវប្រព្រឹត្តទៅតាមអំណាចនៃសភាវធម៌ ដែលជាចំណែកនៃគ្រឿងផ្សំនោះៗ ។ កាលបើមិនជាថាវរៈមាំមួនហើយ ក៏ត្រូវប្រេះឆាបែកធ្លាយទៅយ៉ាងរហ័ស, រូបឯណាត្រូវប្រេះឆា

បែកធ្លាយរហ័ស រូបនោះជារបស់តិច ។ ហេតុដូច្នេះគួរឃើញថា ជីវិតដែលកើតមកអំពីចំណែកនៃគ្រឿងផ្សំ ទើបឈ្មោះថាជារបស់តិចដូចគ្នា ។

ម្យ៉ាងទៀត ជីវិតរលត់ស្មើគ្នានឹងខណៈចិត្ត បើខណៈចិត្តមួយកើតឡើងជីវិតក៏កើតឡើង ខណៈចិត្តរលត់ ជីវិតក៏រលត់ទៅស្មើគ្នា ជីវិតនេះកើតរលត់ៗ យ៉ាងនេះរៀងទៅ ដូចមានព្រះបាលីថា ៖ **អតីតេ ចិត្តក្ខណេ ជីវិត្ថ ន ជីវតិ ន ជីវិស្សតិ** ; **អនាគតេ ចិត្តក្ខណេ ជីវិស្សតិ ន ជីវតិ ន ជីវិត្ថ** ; **បច្ចុប្បន្នេ ចិត្តក្ខណេ ជីវតិ ន ជីវិត្ថ ន ជីវិស្សតិ** (១)

សេចក្តីប្រែថា " **កាលខណៈចិត្តកន្លងទៅហើយ សត្វឈ្មោះថារស់នៅរួចហើយ ឈ្មោះថាកំពុងរស់នៅក៏ទេ ឈ្មោះថានឹងរស់នៅក៏ទេ; កាលខណៈចិត្តមិនទាន់មានមក សត្វឈ្មោះថានឹងរស់នៅ ឈ្មោះថាកំពុងរស់នៅក៏ទេ ឈ្មោះថារស់នៅរួចហើយក៏ទេ; កាលខណៈចិត្តកំពុងកើតឡើង សត្វឈ្មោះថាកំពុងរស់នៅ ឈ្មោះថារស់នៅរួច**

(១) ខុទ្ទកនិកាយ មហានិទ្ទេស ។

**ហើយក៏ទេ ឈ្មោះថានឹងរស់នៅក៏ទេ;** ។ មានសេចក្ដីមួយបទទៀត ដែលគួរលើកយកមកថ្លែងក្នុងទីនេះគ្រាន់ជាគ្រឿងសន្និដ្ឋាន ។ សេចក្ដីថា ៖ **អប្បញ្ហិទំ ជីវិតមាហុ ធិរា** " **ធីរជនទាំងឡាយពោលទុកថា ជីវិតនេះតិចតួច** ″; ពាក្យដែលព្រះសារីបុត្តត្ថេរលោកពោលទុកថា " **ជីវិតនេះ មានតិចតួច** ″ នេះក៏អាស្រ័យដោយលក្ខណៈពីរប្រការ គឺជីវិតនេះតាំងនៅតិច ១, ជីវិតនេះមានការរស់នៅតិច ១ ។ សេចក្ដីខាងលើនេះល្អិតជ្រាលជ្រៅ, លំដាប់តទៅ សូមអធិប្បាយសេចក្ដីខាងលើនេះឲ្យងាយស្ដាប់បាន; ពាក្យដែលថា ជីវិតតាំងនៅតិចនោះ គេអាចនឹងស្ដាប់សេចក្ដីពីរយ៉ាងទៀត គឺមួយតិចដោយធម្មតាមួយទៀតតិចដោយល្អិត ។ ដែលថា ជីវិតតិចដោយធម្មតានោះ លោកពោលទុកក្នុងជរាសូត្រថា ៖

**អប្បំ វត ជីវិតំ ឥទំ ឱរំ វស្សសតាបិ មិយ្យតិ យោ ចេបិ អតិច្ច ជីវតំ អថខោ សោ ជរសាបិ មិយ្យតិ**

ប្រែថា " **ជីវិតនេះតិចណាស់ហ្ន៎! សត្វតែងស្លាប់អំពីខាងអាយនៃអាយុមួយរយឆ្នាំដោយច្រើន បើទុកជាអ្នកណារស់នៅកន្លងហួសពីមួយរយឆ្នាំទៅ អ្នកនោះក៏ត្រូវតែស្លាប់**

ក្នុងកាលចាស់ជរាគ្រាំគ្រាមិនខាន ” ។

ដែលថា ជីវិតតិចដោយល្អិតនោះ លោកសំដែងថា ជីវិតនេះតាំងនៅត្រឹមតែខណៈចិត្តមួយ ដូចបទថា ៖

**ជីវិតំ អត្តភាវោ ច សុខទុក្ខា ច កេវលា ឯកចិត្តសមាយុត្តា លហុសោ វត្តតិក្ខណោ**

ប្រែថា “ **ជីវិតក្តី អត្តភាពក្តី សេចក្តីសុខទុក្ខទាំងអស់ក្តី ប្រព្រឹត្តទៅស្មើគ្នានឹងខណៈចិត្តតែមួយ ឯខណៈចិត្ត តែងប្រព្រឹត្តទៅរហ័ស** ។ **ចិរស្សាមិ នាម ឧប្បជ្ជន្តិ វយនិ ច សភាវធម៌ទាំងឡាយមានជីវិតជាដើម តែងវិនាសទៅវិញរហ័សដូចគ្នានឹងផ្លេកបន្ទោរក្នុងអាកាស** ” ។

ដោយន័យនេះ ជីវិតរបស់សត្វទាំងឡាយ តែងតាំងនៅត្រឹមតែខណៈចិត្តមួយ ក្នុងខណៈចិត្តមួយ ដែលជីវិតតាំងនៅនោះ សត្វដែលជាម្ចាស់នៃជីវិត ឈ្មោះថា **ជីវតិ** “ **កំពុងរស់នៅ** ”, ខណៈចិត្តដែលកើតមុនអំពីខណៈចិត្តនេះ ឈ្មោះថា **ជីវិត្ថ** “ **រស់នៅរួចហើយ** ” ចំណែកខណៈចិត្តជាអនាគតដែលមិនទាន់កើតនោះ ឈ្មោះថា **ជីវិស្សតិ** “ **នឹងរស់នៅ** ” ។ គួរជ្រាបថា ជីវិតបច្ចុប្បន្ន

នេះអាចតាំងនៅបានត្រឹមតែខណៈចិត្តមួយប៉ុណ្ណោះ មិនអាចតាំងនៅបានដោយខណៈចិត្តមួយទៀតឡើយ ។

- ជីវិតដែលតិចយ៉ាងល្អិតដូចសំដែងមកដូច្នេះនេះ ជាធម្មជាតិដែលមើលឃើញដោយលំបាក អ្នកដែលមិនបានគិតពិចារណាច្រើនក៏អាចពោលបានថា បើជីវិតរបស់សត្វទាំងឡាយ តាំងនៅត្រឹមតែខណៈចិត្តមួយប៉ុណ្ណោះពិតហើយ ចុះសត្វទាំងឡាយនឹងស្លាប់ស្មើគ្នានឹងកិរិយាប៉ប្រិចភ្នែកម្តងមែនទេ? សេចក្តីនេះ សូមតបថា ៖ " **មែន** " តែជីវិតសត្វទាំងឡាយ ដែលតាំងនៅត្រឹមតែខណៈចិត្តមួយនោះ តែកាលណារលត់ទៅហើយ ក៏កើតឡើងថ្មីព្រមជាមួយគ្នានឹងខណៈចិត្តថ្មីវិញ ជាប់គ្នាយ៉ាងនេះរៀងទៅហៅតាមភាសាបាលីថា **សន្តតិ** គឺកិរិយាដែលខណៈចិត្តចាស់និងខណៈចិត្តថ្មីកើតរលត់តៗគ្នាមិនចេះឈប់ មិនចេះដាច់; ការរលត់នៃជីវិតមួយខណៈៗដូច្នេះ ក៏ឈ្មោះថាមរណៈ គឺស្លាប់ដូចគ្នាដែរ តែឃើញបានដោយលំបាក; មរណៈដូច្នេះហៅថា **ខណិកមរណៈ** គឺសេចក្តីស្លាប់កំបាំង ។ កាលបើ **សន្តតិ** កិរិយាតគ្នានៃខណៈចិត្ត មិនកើតឡើងទេ គឺជីវិតចាស់រលត់ទៅហើយ ជីវិតថ្មីក៏មិនកើតឡើងទៀត, មរណៈ គឺសេចក្តីស្លាប់របស់សត្វទាំង-

ឡាយ ទើបប្រាកដជាក់ច្បាស់ដល់អ្នកដទៃ មរណៈដូច្នេះហៅថា **អបជិច្ឆន្នមរណៈ** គឺសេចក្តីស្លាប់ដែលមិនកំបាំង ។ ប្រៀបដូចជាធូប ១ សរសៃដែលគេដុតឲ្យឆេះខាងចុងហើយគ្រវីឲ្យវិលជាវង់មូល នឹងឃើញភ្លើងដែលឆេះនៅចុងធូបនោះ មានវង្វង់មូលជាប់គ្នា យ៉ាងណាជីវិតក៏ដូច្នោះ ព្រោះមានសន្តតិជាប់គ្នាមិនដាច់ ទើបឃើញថាជីវិតនេះ ជាប់តៗគ្នាជានិច្ចទៅដូចជារបស់តែមួយ, តែសេចក្តីដែលពិតនោះមិនដូច្នោះឡើយ ។ ជីវិតតែងកើតឡើងហើយរលត់ទៅវិញជាប់តរៀងគ្នាទៅ ដូចជាភ្លើងធូបដូច្នោះៗដែលពិតនោះ មិនមែនភ្លើងជាវង់មូលដូចភ្នែកយើងឃើញទេ តែអាស្រ័យភ្លើងនៅចុងបំផុតនៃធូប នឹងអាស្រ័យដោយការគ្រវីយ៉ាងញាប់រហ័សផង ទើបឃើញជាវង់មូលដូច្នោះឯង ។ ម្យ៉ាងទៀត (បើប្រៀបឲ្យឃើញតាមសម័យឥឡូវ) ដូចហ្វីលម៍កុន កាលបើយើងមើលរូបភាពត្រង់ហ្វីលម៍ យើងឃើញរូបមួយសង្កាត់ៗ មួយៗតរៀងទៅ តែកាលបើយើងមើលត្រង់ស្រមោលដែលចាំងទៅជាប់នឹងផ្ទាំងសំពត់វិញ យើងនឹងឃើញរូបជាប់តៗគ្នាដូចឃើញដើរប្រែរត់ពិតៗជាដើម សេចក្តីទាំងនេះ អាស្រ័យហ្វីលម៍ដែលវិលទៅយ៉ាងរហ័ស ដោយកំលាំងចក្រកាល

គេបញ្ចេញស្រមោលមានឧបមាដូចម្តេច ជីវិតក៏ដូច្នោះ គឺជីវិតត្រូវផ្លាស់ប្តូរទៅគ្រប់ខណៈចិត្ត ជាសង្កាត់ៗតទៅ តែអាស្រ័យសន្តតិទើបឃើញ ជីវិតដូចជាជាប់គ្នាតែមួយវែងទៅតាំងពីកើតមករហូតដល់អស់អាយុ ។

ពាក្យថា ជីវិតមានការរស់នៅតិចនោះ ព្រោះជីវិតប្រព្រឹត្តទៅជាប់ជាមួយគ្នា នឹងខ្យល់ដកដង្ហើមចេញចូល (អស្សាសបស្សាសៈ) ជាដើម ដែលជាឫសគល់ជាប់មាំមួនជាដើម ។ កាលបើជីវិតនៃសត្វមានការរស់នៅមិនគ្រប់គ្រាន់ ល្មមដល់សេចក្តីត្រូវការ ជីវិតក៏ត្រូវបែកធ្លាយទៅបាន ។

ដើម្បីនឹងឲ្យអស់លោក-អ្នកទាំងឡាយ យល់ច្បាស់ថាជីវិតនេះជារបស់តិចពិតមែន សូមដកស្រង់យកសេចក្តីប្រៀបធៀបក្នុងមរកសូត្រ ក្នុងគម្ពីរអង្គុត្តរនិកាយមកចារិកក្នុងទីនេះជាគ្រឿងពង្រីកសេចក្តីឲ្យទូលាយឡើង ដូចសេចក្តីតទៅនេះ ៖

១. ដំណក់ទឹកសន្សើម ដែលធ្លាក់ជាប់នៅលើចុងស្មៅឬស្លឹកឈើក្នុងរាត្រី, លុះព្រឹកឡើងត្រូវពន្លឺរស្មីកំដៅព្រះអាទិត្យ ក៏រីងហួតស្ងួតបាត់ទៅ, មានឧបមាដូចម្តេច;

ជីវិតរបស់យើង កាលដែលប៉ះពាល់ដោយកំដៅធម៌ចាស់ជរា រោគាពាធ និងសេចក្ដីស្លាប់ ក៏រលត់រលាយបាត់បង់ទៅ ដូច្នោះដែរ ។

២. ក្រពេញទឹក ដែលពុះពងឡើងហើយរលាយបាត់ទៅវិញ មានឧបមាយ៉ាងណា; ជីវិតក៏អាស្រ័យហេតុកើតឡើងហើយរលត់ទៅវិញ ព្រោះរលត់ហេតុយ៉ាងនោះដែរ ។

៣. ដុំសាច់ដែលបុគ្គលយកទៅបង់ក្នុងខ្ទះដែកកំពុងក្ដៅខ្លាំង តែងរីងហួតឆាប់ទៅ យ៉ាងណា; រាងកាយរបស់សត្វដែលត្រូវរោគដុតកំដៅ ក៏រីងស្ងួតរហ័សទៅយ៉ាងនោះដែរ ។

៤. ទ-ទឹកដែលហូរចុះអំពីកំពូលភ្នំ ចេញទៅកាន់សមុទ្រជ្រាលជ្រៅ តែងផាត់យកមែកឈើ គល់ឈើ ដុំក្រួស ដីខ្សាច់ទៅផង យ៉ាងណា; ថ្ងៃនិងយប់ដែលកន្លងទៅ ក៏មិនមែនកន្លងទៅទទេឯកឯងឡើយ តែងធ្វើអាយុសត្វឲ្យថយចុះ ហើយនាំយកអាយុសត្វទៅជាមួយគ្នាយ៉ាងនោះដែរ ។

៥. គោដែលគេនាំយកទៅសម្លាប់ កាលបើដើរទៅ

បានមួយជំហានៗ ក៏ឈ្មោះថារំកិលទៅជិតកាន់សេចក្ដីស្លាប់គ្រប់ជំហានជើង; ជីវិតដែលកន្លងទៅរាល់ថ្ងៃ ក៏ឈ្មោះថារំកិលចូលទៅជិតកាន់សេចក្ដីស្លាប់រាល់ថ្ងៃ ដូច្នោះដែរ ។

សេចក្ដីប្រៀបធៀបទាំង ៥ ប្រការ ដែលលើកយកមកថ្លែងនេះ ល្មមទុកជាគ្រឿងចង្អុលប្រាប់ ឲ្យឃើញបានថាជីវិតនេះជារបស់តិច មិនស្ថិតស្ថេរមាំមួនឡើយ ហេតុអ្វីក៏បានជាយើង បបួលគ្នាប្រមាទធ្វេសប្រហែសម្ល៉េះ? ដូចម្ដេចក៏មិនខំធ្វើខ្លួនឲ្យមានប្រយោជន៍ឡើង? ដល់ពេលដែលលះបង់អត្តភាពនេះទៅ នឹងបានទៅកាន់សេចក្ដីល្អមិនខូចបង់ជាតិកំណើត តែសត្វលោកដែលលិចជ្រមុជជ្រមុលនៅក្នុងសេចក្ដីល្ងង់ខ្លៅ មិនបានស្ដាប់ពាក្យឱវាទប្រៀនប្រដៅរបស់ពុទ្ធាទិបណ្ឌិត រមែងស្រវឹងវង្វេងភាន់ច្រឡំថា ខ្លួនមិនទាន់ចាស់ជរា ក្នុងពេលដែលខ្លួនកំពុងចាស់ជរា ។ ហេតុនេះ ទើបឃើញថាសត្វលោកនេះមានចិត្តរឹងត្អឹងណាស់ បើទុកជាឃើញមនុស្ស ដែលត្រូវជរាបៀតបៀនឲ្យសក់ស្កូវ, ភ្នែកខ្វាក់, ធ្មេញបាក់, ត្រចៀកថ្លង់, ថ្ពាល់ផត, ខ្នងកោង, សាច់ស្បែកជ្រួញជ្រីវយុរយា, ដៃកាន់ឈើច្រត់ញ័រទទ្រើតឬពុំនោះ ឃើញមនុស្សឈឺ

ស្គាំងស្គម សាច់ស្លេកស្លាំង ពោះផតជាប់ជល់ឆ្អឹងខ្នង ដង្ហើមផតប៉ោងៗ ប៉ផ្តឹតប៉ផ្តក់ដេកទន្ទឹងចាំតែពេល ឬក៏ឃើញមនុស្សស្លាប់ ដែលមានញាតិសន្តានព្រៀងលានទ្រហោយំកងរំពង សោកស្រណោះអាឡោះអាល័យ ក៏សត្វលោកធ្វើព្រងើយ ហាក់ដូចជាគល់ឈើ គ្មានចិត្ត គ្មានវិញ្ញាណ, សូម្បីព្រះពុទ្ធជាម្ចាស់ក៏ទ្រង់លាន់ព្រះឱស្ឋទៅរកពួកស្ត្រីជាមិត្រនាងវិសាខាថា ៖

**កោ នុ ហាសោ កិមានន្ទោ និច្ចំ បជ្ជលិតេ សតិ**
**អន្ធការេន ឱនទ្ធា បទីបំ ន គវេសថ**

ប្រែថា ៖ " **កោតតែសើចកើតដែរ!!! កោតតែរីករាយទៅកើតដែរហ្ន៎!!! បើភ្លើងរាគៈ ទោសៈ មោហៈ ដុតឲ្យក្តៅរោលរាលជានិច្ច, អ្នកទាំងឡាយ, កាលបើសេចក្តីងងឹតគឺអវិជ្ជាគ្របសង្កត់ (យ៉ាងនេះ) ហេតុដូចម្តេចក៏មិនខំស្វែងរកប្រទីបថ្វាលា គឺព្រះនិព្វាន (ដើម្បីនឹងកំចាត់នូវសេចក្តីងងឹតទាំងនោះចោលចេញទៅ)** " ។

ព្រោះជីវិតដែលជារបស់តិច ដូចបានពោលមកហើយ ទើបព្រះសម្មាសម្ពុទ្ធទ្រង់ទូន្មានមិនឲ្យប្រមាទក្នុងជីវិត គឺកុំមើលងាយថាអាយុស្ថិតស្ថេរនៅបានវែងឆ្ងាយ ដោយព្រះ

បាលីថា ៖

**អប្បមាយុ មនុស្សានំ ហិលេយ្យ នំ សុបោរិសោ**
**ចរេយ្យា ទិត្តសីសោវ នត្ថិ មច្ចុស្ស នាគមោ ។**

ប្រែថា ៖ " **អាយុរបស់សត្វទាំងឡាយតិចពេក, បុរសមានប្រាជ្ញាគួរជិនណាយនឹងអាយុតិចនោះទៅ (កុំទុកចិត្តថា) សេចក្តីស្លាប់នឹងមិនមកដល់ខ្លួននោះឡើយ, ដូចជាបុគ្គលដែលត្រាច់ទៅទាំងភ្លើងកំពុងឆេះនៅលើក្បាល(នឹងថាមិនឆេះខ្លួនស្លាប់នោះក៏ឥតអង្គឹមានឡើយ)**" ។

នរជនទាំងឡាយ គួរសិក្សាហាត់ប្រព្រឹត្តសុចរិតធម៌ ដោយការប្រកាន់យកជីវិតតិចជានិមិត្ត; ដោយព្រះបាលីថា ៖

**តស្មា ហិ សិក្ខេថ ឥធេវ ជន្តុ**
**យំកិញ្ចិ ជញ្ញា វិសមន្តិ លោកេ**
**ន តស្ស ហេតុ វិសមំ ចរេយ្យ**
**អប្បញ្ហិទំ ជីវិតមាហុ ធីរា** [១] ។

ប្រែថា ៖ " **ព្រោះហេតុនោះហើយ សត្វក្នុងលោកនេះ**

(១) គុហដ្ឋកសូត្រ ខុទ្ទកនិកាយ ។

**គួរសិក្សាទូន្មានប្រៀនប្រដៅខ្លួន, គួរដឹងថាកិច្ចការឯណានីមួយក្នុងលោកនេះថា ជាការមិនស្ងប់ គួរកុំប្រព្រឹត្តនូវធម៌មិនស្ងប់ ព្រោះហេតុនៃការមិនស្ងប់នោះ អ្នកប្រាជ្ញទាំងឡាយលោកពោលថា ជីវិតនេះតិចណាស់ ″ ។** ព្រោះសត្វទាំងឡាយ សុទ្ធតែមានសេចក្ដីស្លាប់នៅខាងចុងគ្រប់ៗប្រាណ ។

## ២. មានជរាជាធម្មតា

សេចក្ដីចាស់ជរាគ្រាំគ្រា ជាសម្បត្តិប្រចាំជីវិត, បុគ្គលដែលប្រសូតចាកគភ៌មាតាមក ពិតមែនតែឥតមានអ្វីជាប់តាមខ្លួនមក តែគង់មានរបស់ដែលជាធម្មជាតិប្រគល់ឲ្យជាសម្បត្តិជាប់នឹងខ្លួនមក ។ សម្បត្តិនោះមាន ៣ ប្រការ គឺជរា សេចក្ដីចាស់គ្រាំគ្រា ១, ព្យាធិ ការឈឺចាប់ ១, មរណៈ សេចក្ដីស្លាប់ ១; យ៉ាងនេះ ក៏ឥតមានអ្នកណាមួយគិតដល់ឡើយ, អ្នកខ្លះចូលចិត្តយ៉ាងខ្លីៗថា ជរា ការចាស់គ្រាំគ្រា ក៏គឺអាការៈដែលបាក់បែក ស្គាំងស្គមស្បែកជ្រួញជ្រីវ, ភ្នែកងងឹត, ត្រចៀកថ្លង់, ខ្នងកោង, ថ្ពាល់ផតប៉ុណ្ណោះជាដើម ។ បើចូលចិត្តពាក្យថា ចាស់ជរាត្រឹមតែប៉ុណ្ណោះ ក៏នៅខ្លីសេចក្ដីណាស់ ព្រោះថាបើអាការៈទាំង

អស់នេះ នៅមិនទាន់ប្រាកដដល់ភ្នែកត្រឹមណា ក៏នៅគិតថា ខ្លួននៅកំឡោះ ក្រមុំត្រឹមនោះ ។ មនុស្សដែលគិតត្រឹមតែប៉ុណ្ណោះ ឈ្មោះថាជាអ្នកស្រវឹងនៅក្នុងវ័យ; ដូចក្នុងកាលឥឡូវនេះ ជាសម័យវិទ្យាសាស្ត្រ, មនុស្សលោកអាចកសាងគ្រឿងបំបាំងភ្នែកជាមាយា បិទបាំងគំនិតដោយច្រើនដោយគ្រឿងតែងកាយ ដូចទឹកអប់, ប្រេង, ម្សៅ, គ្រឿងលាប-ផាត់ជាដើម; ដូចមនុស្សចាស់ជរាក៏ឧស្សាហ៍តែងខ្លួនធ្វើឲ្យមានអាការៈប្រហែលនឹងកំឡោះក្រមុំបាន, គ្រឿងអស់នេះ សុទ្ធតែបំភាន់គំនិតទាំងបំពេញសេចក្ដីស្រវឹងឲ្យដល់ខ្លួនថែមទៀត ឬធ្វើខ្លួនឲ្យជាចំណីនៃអវិជ្ជា តណ្ហាទេតើ ។ ដូច្នេះគួរធ្វើសេចក្ដីចូលចិត្តជាថ្មីថាចាស់ជរានោះ មិនមែនមានត្រឹមតែអាការៈ ដែលយើងឃើញដោយភ្នែកប្រក្រតីនោះទេ សូម្បីអាការៈនៃអវយវៈផ្សេងៗដែលចំរើនធាត់ធំឡើង ក៏ឈ្មោះថាជរាដូចគ្នា, មនុស្សគ្រប់រូប ក៏ឈ្មោះថាមានចាស់ជរាមកតាំងអំពីនៅក្នុងគភ៌នៃមាតាតែម្ដង ចាប់ផ្ដើមតាំងអំពីធាតុទាំង ៤ មកចួបផ្គុំផ្សំគ្នាតាមច្បាប់នៃធម្មតា ហើយក៏បណ្ដាលឲ្យមានជរា ធ្វើឲ្យធំគ្រប់នាទី រហូតដល់បែកបញ្ចសាខា ។ ឯចាស់ជរានេះ ក៏មានជានិច្ចរឿយៗទៅរហូតដល់ប្រសូត

តពីនោះមក ក៏ត្រូវជរានាំរឿយៗទៅទៀតតាំងអំពីនៅជាកូនក្មេងតូច ក្មេងចេះក្រឡាប់, ចេះអង្គុយ, ចេះដើរតេះតះ, ចេះនិយាយ រហូតដល់ពេញកំឡោះ ក្រមុំជាមនុស្សធំឡើង ហើយឈប់ចំរើនតទៅទៀត ។ ចាប់ផ្តើមតាំងពីមានវ័យវឌ្ឍនាចំរើនឡើង រូបរាងកាយដែលធាត់ធំមាំមួនមានសរីរៈរាងកាយស្រស់បស់ មានសាច់ឈាមឆវីវណ្ណផូរផង់ហ្មត់ហ្មងគួរជាទីជ្រះថ្លា ៖ សេចក្តីចាស់ជរាបែបនេះចាត់ជាសេចក្តីចាស់ជរាធ្វើឲ្យពេញចិត្តនៃមនុស្សគ្រប់គ្នា ។ តអំពីនោះទៅ ត្រូវវេនចាស់គ្រាំគ្រាមនុស្សគ្រប់គ្នាតែងចាស់រៀងៗទៅបន្តិចម្តងៗឥតឈប់ឥតស្រាក ចាស់គ្រប់ដង្ហើមចេញចូល ឥតមានអាការៈនៃរូបធម៌ណាមួយគង់ស្ថិតស្ថេរនៅបានឡើយ តែងផ្លាស់ប្តូរទៅជានិច្ចឥតឈប់ឈរឡើយ រហូតដល់រលំរលាយទៅ ៖ យ៉ាងនេះទើបឈ្មោះថា សត្វត្រូវជរានាំយកទៅហើយ ឥតមានអ្នកណាគេចវេះរត់ពួនបានឡើយ មិនកំណត់ថាមនុស្សបែបណាទេ ទោះបីអ្នកទ័លក្រ ឬអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ អ្នកល្ងង់ខ្លៅឬអ្នកប្រាជ្ញ ក៏សុទ្ធតែនៅក្នុងអំណាចនៃធម៌ចាស់ជរាទាំងអស់ ។ តែចាស់ជរានៃមនុស្សល្ងង់ ឬមនុស្សពាល ឈ្មោះថាចាស់ខុសបែបបទខុសក្រិត្យក្រម

ដូចពាក្យគេតែងនិយាយថា ចាស់ដូង ចាស់ត្នោត ។ ចំណែកខាងចាស់នៃអ្នកប្រាជ្ញ ទើបចាស់គាប់ប្រសើរ មានផលច្រើន, ថ្ងៃខែដែលកន្លងទៅ ក៏កន្លងទៅដោយការងារ ដែលជាប្រយោជន៍ដល់ខ្លួននិងអ្នកដទៃ ។ ការទ្រុឌទ្រោមទៅ ចំពោះតែចំណែកសង្ខារប៉ុណ្ណោះ ឯសេចក្តីល្អឥតរលំរលាយបាត់ទៅឡើយ ។ អ្នកប្រាជ្ញ បើមានវ័យកាន់តែចាស់ឡើង ការចេះដឹងនឹងសេចក្តីល្អ ក៏រឹងរឹតតែចំរើនឡើងទុកជាតឹកតាង ជាគំរូនៃយុវជនខាងក្រោយ ។ មនុស្សបែបនេះទើបឈ្មោះថា កើតហើយដោយល្អ ជាមនុស្សធ្វើលោកឲ្យចំរើន មិនមែនកើតមកគ្រាន់តែបំពេញទឹកដីទេ, ពេលស្លាប់ទៅវិញ គង់ស្លាប់ទៅល្អទៀត គឺស្លាប់ទៅកើតក្នុងស្ថានមនុស្សនេះវិញ ឬកើតក្នុងស្ថានសួគ៌ជាពួកនៃទេវតា ។ អស់លោក-អ្នកទាំង-ឡាយ! ជីវិតរបស់អស់លោក-អ្នក, ឥឡូវនេះ នៅក្នុងកណ្តាប់ដៃនៃជរា, ត្រូវជរានាំយកទៅហើយ, អវយវៈគ្រប់យ៉ាងកំពុងតែទ្រុឌទ្រោមទៅ ឥតមានចំណែកណាមួយគង់វង្សស្ថិតស្ថេរនៅឡើយ ។ គួរគិតពិចារណាមើលរាងកាយរបស់អស់លោក-អ្នក... សក់កំពុងតែស្កូវសព្រោង, ស្បែកកំពុងជ្រួញជ្រីវយុរយារស្វិតស្រពោន ភ្នែកស្រវាំង

ស្រែអស់ហើយ ដៃជើងថមថយកំឡាំង ត្រចៀកថ្លង់ និយាយខ្លាំងទើបឮ ធ្មេញក៏បាក់ ថ្ពាល់ផតគ្រហ៊ុប ។ ចំណែកនាមធម៌ សេចក្តីចេះចាំ ក៏អន់ថយ ស្មារតីមិននៅជាប់នឹងខ្លួន គិតចាំងមុខភ្លេចឯក្រោយ គិតឯណេះភ្លេចឯណោះ, មើលចុះ មនុស្សដែលចាស់ជរាហើយសុទ្ធតែបែបនេះឯង; ចូរយកកញ្ចក់មកឆ្លុះមើល តែកុំមើលដើម្បីឲ្យល្អដែលជាអាហារនៃតណ្ហា; ចូរមើលឲ្យកើតសេចក្តីសង្វេគក្នុងសង្ខារធម៌ ។ បើប្រាកដជាចាស់ជរានាំយកទៅហើយ ចូរប្រញាប់ប្រញាល់ធ្វើសេចក្តីល្អឡើង ធ្វើឲ្យឆាប់ៗទៅ !!! ព្រោះមិនមានអ្នកណាជួយរាំងការពារយើងឲ្យរួចអំពីចាស់ជរានេះបានឡើយ, កាលណាបើត្រូវជរានាំយកទៅហើយក៏ ...

## ៣. មិនមានអ្វីជាទីពឹងពំនាក់ការពារបានឡើយ

បើយើងគិតពិចារណាដោយហ្មត់ចត់ ក៏ឃើញថាជាសេចក្តីពិតយ៉ាងនោះ សូម្បីក្នុងសម័យវិទ្យាសាស្ត្រដែលកំពុងលូតលាស់ចំរើនបរិបូណ៌ មានមនុស្សជាច្រើនដែលបានរៀនសុខវិទ្យា ដែលជាវិជ្ជាសម្រាប់ការពារមិនឲ្យរោគកើតឡើងបាន ក៏គង់ឥតមានអ្នកណាមួយវិសេស អាច

ធ្វើឲ្យមនុស្សផុតពីចាស់ជរាបានឡើយ មនុស្សទាំងអស់នៅតែប្រទះនឹងជរាចាស់គ្រាំគ្រាដូចគ្នាដដែល ។ សេចក្ដីនេះជាគ្រឿងចង្អុលផ្លូវឲ្យឃើញថា ៖ " **មិនមានអ្នកណាមួយការពារបាន** " ។ កាលបើដូច្នេះ គួរជនទាំងឡាយគិតឲ្យឃើញច្បាស់ថាការចាស់គ្រាំគ្រានេះ ជាប៉ែកធម្មតារបស់សង្ខារទេ ។ ឯសង្ខារដែលកើតហើយក្នុងខាងដើម ក៏តែងប្រែប្រួលបែកខ្ទាត់ខ្ទាយរលត់ទៅក្នុងទីបំផុត ។ ការបែកខ្ទាត់ខ្ទាយរលត់សង្ខាររបស់មនុស្សនោះ គេហៅថា ៖ " **សេចក្ដីស្លាប់** " ឯសេចក្ដីស្លាប់នេះជាសត្រូវមួយយ៉ាងកាចដែលមនុស្សគ្រប់គ្នាត្រូវតែជួបប្រទះគេចទៅណាមិនរួចត្រូវនឹងពុទ្ធភាសិតថា ៖ " **សត្វទាំងឡាយទាំងអស់នឹងស្លាប់គ្រប់គ្នាព្រោះជីវិតនេះមានសេចក្ដីស្លាប់ជាទីបំផុត** " សូម្បីរស់នៅបានយូរប៉ុន្មានក៏ត្រូវតែស្លាប់ដែរ សត្វទាំងឡាយ សុទ្ធតែមានសេចក្ដីស្លាប់ជាធម្មតា ព្រោះហេតុនោះ ជនទាំងឡាយគួរដឹងថា ៖

## ៤. សេចក្ដីស្លាប់ជាភ័យធំរបស់សត្វលោក

សត្វលោកទាំងអស់ ខ្លាចសេចក្ដីស្លាប់ក្រៃលែងជាង

ខ្លាចអ្វីៗឯទៀត តែមនុស្សទាំងអស់ត្រូវស្លាប់គ្រប់ៗគ្នាបើទុកជាដឹងពិតប្រាកដថា ៖ " **ខ្លួនត្រូវស្លាប់** " ក៏នៅតែមិនចង់ស្លាប់ដែរ ។ អ្នកខ្លះបើមានគេនិយាយអំពីរឿងសេចក្តីស្លាប់ ក៏យល់ថាជារឿងអពមង្គល ជារឿងមិនគួរនិយាយ ។ មនុស្សបែបនេះឈ្មោះថា **ជាអ្នកខ្លាចសេចក្តីស្លាប់** ។ ឯសេចក្តីស្លាប់មិនមែនជាធម៌ទើបនឹងមានថ្មីៗទេ ជាធម៌មានមកតាំងអំពីចាប់ផ្តើមតួបដិសន្ធិមកតែម្តង ។ ហេតុដូច្នេះ, សត្វទាំងឡាយដែលកើតមកក្នុងលោកនេះ ដែលមានជីវិតកន្លងទៅរាល់ថ្ងៃរាល់យប់ ឈ្មោះថាស្លាប់ទៅរាល់ថ្ងៃរាល់យប់ តែស្លាប់បន្តិចម្តងៗ គឺអាការៈក្នុងរូបរាងកាយស្លាប់ទៅពុំព្រមគ្នា ម្តងស្លាប់នេះ ម្តងស្លាប់នោះ លុះស្លាប់គ្រប់អាការៈពេលណា ទើបឈ្មោះថាស្លាប់មែនទែនក្នុងកាលនោះ ។ សត្វទាំងឡាយដែលស្លាប់ មិនមែនជាស្លាប់ហើយសូន្យទៅទទេទេ បើនៅមានហេតុមានបច្ច័យគ្រប់គ្រាន់ក៏ត្រូវកើតទៀត សត្វលោកដែលស្លាប់ ក៏ទុកដូចជាបានកើតជាថ្មីម្តងទៀត ឬផ្លាស់កន្លែងថ្មីទៀត ។

ក្នុងសាសនាព្រះពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ទូន្មានរំឭក

អំពីសេចក្តីស្លាប់ថា ៖ " **យើងនឹងស្លាប់ សេចក្តីស្លាប់នឹងមានមកដល់យើង យើងនឹងគេចរត់អំពីសេចក្តីស្លាប់ពុំរួចឡើយ** " ។ ដែលទ្រង់ត្រាស់រំឭកដូច្នេះ ក៏ដើម្បីឲ្យពុទ្ធសាសនិកជនរៀនហាត់ស្ទៀតតតាំង នឹងសេចក្តីស្លាប់នោះឯងឲ្យហើយទៅ ដល់វេលាស្លាប់ក៏ស្លាប់ដោយមានស្មារតី មិនវង្វេងស្លាប់, មនុស្សដែលស្លាប់មិនវង្វេង ក៏តែងបានសេចក្តីសុខក្នុងលោកទាំងពីរគឺ លោកនេះ និង លោកខាងមុខព្រោះនឹកថា ៖ " **បុណ្យអញបានធ្វើហើយ សេចក្តីល្អអញបានធ្វើហើយ** " តែមនុស្សពួកខ្លះ កាលនឹកដល់សេចក្តីស្លាប់ហើយ ក៏មិនធ្វើអ្វីអាល័យតែអង្គុយចាំស្លាប់ ដេកចាំស្លាប់, ធ្វើដូច្នេះខុសឆ្គងណាស់នឹងបំណងព្រះពុទ្ធជាម្ចាស់ បើយើងនឹកដល់សេចក្តីស្លាប់ ក៏ត្រូវដឹងខ្លួនឲ្យច្បាស់លាស់ថា យើងនឹងត្រូវស្លាប់ ក្នុងថ្ងៃណាមួយមិនខាន ហើយមិនប្រមាទ ប្រញាប់ប្រញាល់កំចាត់សេចក្តីអាក្រក់ចោលចេញ ហើយស្វែងរកសេចក្តីល្អ យកមកតម្កល់ទុកនៅក្នុងចិត្ត, នោះទើបត្រឹមត្រូវតាមពុទ្ធបំណង ។ ហេតុដូច្នេះអ្នកដែលខ្លាចសេចក្តីស្លាប់ មិនគួរធ្វើព្រងើយៗឡើយ គួរតែប្រឹងប្រែងធ្វើបុណ្យ គឺសេចក្តីល្អទុកឲ្យឆាប់ទៅ ព្រោះ..

# ៥. ការបំពេញបុណ្យ ជាគ្រឿងនាំសុខមកប្រគល់ឲ្យ

សួរថា បុណ្យគឺអ្វី? អ្វីជាបុណ្យ?

ឆ្លើយថា បុណ្យគឺសេចក្ដីសុខ, សេចក្ដីសប្បាយចិត្ត, ត្រជាក់ចិត្ត, ស្ងប់ចិត្ត, រីករាយក្នុងចិត្ត ដែលកើតអំពីការធ្វើសេចក្ដីល្អណាមួយដោយមិនលោភ, មិនក្រោធ, មិនវង្វេង ។ ម្យ៉ាងទៀត គុណជាតិដែលធ្វើចិត្តឲ្យបរិសុទ្ធចាកសេចក្ដីសៅហ្មងក៏ហៅថា " **បុណ្យ** " តែកុំច្រឡំ, មិនមែនសប្បាយរីករាយ ដូចមើលកុនមើលល្ខោននោះទេ ។ ការរីករាយសប្បាយទាំងនេះ កើតមកអំពីរាគចិត្ត[១] មិនមែនជាតួបុណ្យឡើយ ។ ចុះអ្វីជាហេតុនៃបុណ្យ?

- **អលោភៈ** ចិត្តមិនជាប់ជំពាក់ក្នុងទ្រព្យធនជាដើម;
- **អទោសៈ** ចិត្តមិនប្រទូស្ត (តែងប្រកបដោយមេត្តាករុណា);
- **អមោហៈ** ចិត្តមិនស្រវឹងមួម៉ៅ (តែងប្រកបដោយសេចក្ដីយល់ត្រូវឃើញត្រូវ) ។

(១) រាគ សំ. បា. ( ន. ) (រាគ) តម្រេក, សេចក្ដីរីករាយ, ត្រេកត្រអាល ចំពោះកាម : ត្រូវរាគៈគ្របសង្កត់ ។ រាគចិត្ត ចិត្តដែលប្រកបដោយរាគៈ ។

នេះជាហេតុនៃបុណ្យ ។ បុណ្យនេះកុំចូលចិត្តថាស្ថិតនៅក្នុងវត្ថុផ្សេងៗឡើយ បុណ្យនៅក្នុងចិត្តយើងនេះឯង យើងមិនត្រូវទៅរកបុណ្យ ឬសូមបុណ្យអំពីទីដទៃឡើយ ត្រូវរកបុណ្យតែក្នុងចិត្តយើងក៏បានហើយ ព្រោះកាលណាបុណ្យកើតមានក្នុងចិត្តហើយ ក៏អាចបណ្តាលឲ្យបំពេញធ្វើនូវបុញ្ញកិរិយាវត្ថុទាំង ១០ យ៉ាងមាន ទាន សីល ភាវនាជាដើមបាន ។ មនុស្សខ្លះធ្វើបុណ្យមកយូរហើយ តែមិនស្គាល់ថាបុណ្យនោះដូចម្តេច, កាលបើមិនស្គាល់បុណ្យ បុណ្យក៏មិនងាយកើតឡើង ។ ហេតុដូច្នេះ យើងជាអ្នកត្រូវការចង់បានបុណ្យ គួរតែស្គាល់បុណ្យឲ្យច្បាស់ ការធ្វើបុណ្យមិនមែនសម្រាប់ទុក យកផលក្នុងអនាគតជាតិតែម្យ៉ាងនោះឡើយ, ធ្វើបុណ្យកាលណាបានផលកាលនោះ ព្រោះបុណ្យអាចឲ្យផលតាំងពីក្នុងបច្ចុប្បន្នកាលនេះទៅ ។ ម្យ៉ាងទៀតបុណ្យនេះ អ្នកធ្វើបុណ្យកាលបើពិចារណាសង្កេតមើលដោយល្អិត ក៏អាចដឹងដោយប្រាជ្ញារបស់ខ្លួន ឬមើលឃើញដោយភ្នែករបស់ខ្លួនបាន មិនចាំបាច់អ្នកណាប្រាប់ឡើយ ។ អ្នកណាមានបុណ្យច្រើន អ្នកនោះក៏សប្បាយរីករាយច្រើន បើមានបាបច្រើន ក៏លំបាកច្រើន, បុណ្យបាបជាធម៌គូនឹងគ្នាតែ

មិនត្រូវគ្នាទេ, ដូចពុទ្ធភាសិតថា ៖

**ន ហិ ធម្មោ អធម្មោ ច  ឧភោ សមវិបាកិនោ**
**អធម្មោ និរយំ នេតិ  ធម្មោ បាបេតិ សុគតឹ**

" **ធម៌ពីរយ៉ាងគឺ បុណ្យនិងបាប មានផលមិនស្មើគ្នាទេ បាបនាំសត្វឲ្យទៅកើតក្នុងនរក, បុណ្យនាំសត្វឲ្យកើតក្នុងសុគតិភព** " ។ បើបុណ្យកំពុងឲ្យផល, បាបក៏នៅស្ងៀម បើត្រូវបាបឲ្យផលវិញ, បុណ្យក៏ត្រូវវេនឈប់; ហេតុនោះត្រូវព្យាយាមខំធ្វើចិត្ត ឲ្យជាបុណ្យដរាប កុំឲ្យបាបមានឱកាសចូលមកនៅក្នុងចិត្តបាន ជាការហ្វឹកហាត់បង្គាប់ចិត្តខ្លួនឯង, មិនបណ្តែតបណ្តោយចិត្ត ឲ្យប្រព្រឹត្តទៅតាមកាមារម្មណ៍ផ្សេងៗ ។ អ្នកណាដែលមិនចេះទូន្មានចិត្តឲ្យនៅក្នុងកណ្តាប់ដៃខ្លួន ប្រៀបដូចជាទូកដែលឥតមានអ្នកកាន់ចង្កូត តែងអណ្តែតទៅតាមខ្សែទឹក, តាមខ្យល់ផាត់ ជួនកាលត្រូវខ្យល់ផាត់បោកត្រឡប់ - ត្រឡិនលិចទៅក៏មាន ជួនកាលអណ្តែតទៅប៉ះនឹងដុំថ្មបែកធ្លាយទៅក៏មាន; ពុំនោះសោត ដូចមនុស្សភ្នែកខ្វាក់ឥតមនុស្សដឹកដៃ; ដើរទៅត្រូវផ្លូវខ្លះ, ខុសផ្លូវខ្លះ; ចិត្តក៏ដូច្នោះដែរ ។ បើយើងបណ្តែតបណ្តោយទៅតាមទំនើង

ហើយ តែងទៅច្ចូបប្រទះនឹងអភិជ្ឈា[១], ទោមនស្ស[២] ដែលជាអកុសលធម៌ ធ្វើឲ្យចិត្តសៅហ្មងខូចកើតក្ដៅក្រ-ហាយជានិច្ចរឿយៗ ។ ការធ្វើចិត្តមិនឲ្យអណ្ដែតអណ្ដូងឬប្រើចិត្ត ទូន្មានចិត្ត ឲ្យគិតតែអំពើខាងបុណ្យ ខាងល្អតែងមានផលានិសង្សច្រើន, ការទប់ចិត្តបានដូច្នោះ ក៏ព្រោះមានសតិសម្បជញ្ញៈ គឺមានស្មារតីដឹងខ្លួនជាគ្រឿងរារាំងបាប ហើយព្យាយាមដុតបំផ្លាញភ្លើងទុក្ខ ភ្លើងកិលេសជានិច្ច ។ **សតិ** និង **សម្បជញ្ញៈ**នេះ ជាធម៌មានគុណូបការៈច្រើនដល់មនុស្សទាំងឡាយ ។ មនុស្សដែលគ្មានសតិសម្បជញ្ញៈបើទុកជារស់នៅ លោកឲ្យឈ្មោះថាជាមនុស្សស្លាប់ គឺស្លាប់ស្មារតី ។ អ្នកដែលមានស្មារតីដឹងខ្លួន បើទុកជាស្លាប់បាត់ទៅហើយក៏ឈ្មោះថារស់នៅព្រោះស្លាប់បាត់ទៅតែរូបកាយ ត្រង់សេចក្ដីល្អដែលបានធ្វើទុកអាចស្ថិតនៅទាំងអស់ ហើយនាំឲ្យទៅកើតក្នុងសុគតិ ។ ដែលយើងថាស្លាប់ៗនោះ គឺជាឈ្មោះនៃការ

---

(១) អភិជ្ឈា អៈភិច-ឈា បា.; សំ. (ន.) (អភិធ្យា) គំនិតសម្លឹងរំពៃរកទំនងឲ្យបានទ្រព្យអ្នកដទៃមកជារបស់ខ្លួន; ការចង់បានហួសហេតុហួសទំនង; តណ្ហា; អភិលាស : អភិជ្ឈាជាទុច្ចរិតមួយខាងផ្លូវចិត្ត រាប់ចូលជាមនោទុច្ចរិត មួយក្នុងមនោទុច្ចរិត ៣ យ៉ាង ។

(២) ទោមនស្ស ទោមៈនាស់ បា. (ន.) សេចក្ដីតូចចិត្ត, សេចក្ដីអាក់អន់ចិត្ត : ចិត្តប្រកបដោយទោមនស្ស, មានទោមនស្ស ។

បែកធ្លាយធាតុទាំង ៤ ដែលហៅថារូបនោះឯង ។ ឯវិបាកចិត្តជារូបនៃអំពើបុណ្យ-បាប ដែលទៅចាប់កំណើតទៀតនោះ មិនចេះស្លាប់បាត់សូន្យទេ ព្រោះចិត្តនោះកើតរលត់ៗជាធម្មតា ។ ម្យ៉ាងទៀត ស្មារតីនេះក្នុងពេលដែលចិត្តប្រកបដោយបាបធម៌គឺ សេចក្តីលោភ, សេចក្តីក្រោធ ឬ ឥច្ឆាព្យាបាទក៏អាចដឹងខ្លួនបាន, កាលបើដឹងហើយត្រូវគិតរកហេតុថាបាបធម៌នោះកើតមកពីអ្វី កាលបើរកហេតុឃើញហើយ ក៏អាចកំចាត់បង់ចោលបានភ្លាម ។ លុះកំចាត់បាបធម៌បានហើយ ចិត្តក៏ស្អាតបរិសុទ្ធហៅថាចិត្តបុណ្យ ឬហៅថាបុណ្យកើតឡើងក្នុងចិត្ត, បុណ្យនេះអាចនាំសេចក្តីសុខមកឲ្យយើងបានគ្រប់កាល, ទោះបីយើងស្លាប់ទៅហើយ បុណ្យនេះ ក៏ជូនជាប់តាមនឹងខ្លួនយើងទៅ ជួយជ្រោមជ្រែងឲ្យយើងបានល្អ បានសុខ; ដូចពុទ្ធភាសិត ថា ៖ **នាយេវ អនុគាមិនី** " **បីដូចស្រមោលអន្ទោលតាមប្រាណ** " ។ ហេតុនេះសាធុជនបុរសស្ត្រី គួរបំពេញបុណ្យឲ្យបានច្រើន ទុកក្នុងខ្លួនដើម្បីធ្វើចិត្តឲ្យជ្រះថ្លាផូរផង់ កុំឲ្យប្រឡាក់ដោយបាប ព្រោះការសន្សំបុណ្យឲ្យច្រើននេះ ជាហេតុនាំសេចក្តីសុខច្រើនមកឲ្យយើង ។

ក្នុងទីបំផុតនេះ សូមបង្រួមសេចក្ដីឲ្យខ្លីចុះដូចតទៅនេះ ៖

សត្វលោកទាំងអស់ដែលកើតមកហើយ ក្នុងសំសារវដ្ដសុទ្ធតែត្រូវ អវិជ្ជា, តណ្ហា, ឧបាទាន, កម្មញាំញីឲ្យកើតទៅតាមទំនងផលដែលខ្លួនធ្វើទុក, បើធ្វើល្អ ក៏បានផលល្អ បើធ្វើអាក្រក់ ក៏បានផលអាក្រក់ នឹងគេចអំពីផលកម្មនេះមិនបានឡើយ សមដូចពុទ្ធភាសិតដែលព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ទុកថា ៖

**ឧភោ បុញ្ញញ្ច បាបញ្ច យំ មច្ចោ កុរុតេ ឥធ តញ្ហិ តស្ស សកំ ហោតិ តញ្ច អាទាយ គច្ឆតិ**

ប្រែថា " **សត្វបានធ្វើអំពើណាទុកក្នុងលោកនេះ ទោះជាបុណ្យក្ដី បាបក្ដី ទាំងពីរយ៉ាង អំពើបុណ្យ-បាបនោះជារបស់សត្វនោះ, សត្វនោះតែងយកអំពើទាំងពីរផ្នែកនោះជាប់នឹងខ្លួនទៅផង** " ។

**យាទិសំ វបតេ ពីជំ តាទិសំ លភតេ ផលំ កល្យាណការី កល្យាណំ បាបការី ច បាបកំ**

ប្រែថា " **បុគ្គលដាំពូជបែបណា រមែងបានផលបែបនោះ, បុគ្គលធ្វើអំពើល្អតែងបានផលល្អ បុគ្គលធ្វើអំពើ**

អាក្រក់តែងបានផលអាក្រក់ ″ ។

ឬដូចសុភាសិតមួយបទទៀតថា ៖

**បុព្វេ ទានាទិកំ កត្វា ឥទានិ លភតេ សុខំ**
**មូលេវ សិញ្ចិតំ ហោតិ អគ្គេ ច ផលទាយកំ**

ប្រែថា ‶ **បុគ្គលធ្វើអំពើជាកុសល មានទានជាដើមទុកក្នុងកាលមុន រមែងបានសេចក្ដីសុខក្នុងកាលឥឡូវនេះ, ប្រៀបដូចជាបុគ្គលស្រោចទឹកត្រង់គល់ឈើ តែត្រូវបេះយកផ្លែលើចុងឈើវិញ** ″ ។

បុគ្គលកើតមកក្នុងលោកនេះ ប្រសិនណាបើមិនតជាប់មកអំពីកម្មចាស់ទេ នឹងទៅជាមនុស្សដូចគ្នាទាំងអស់ តែបានជាមិនដូចគ្នា ព្រោះអំពើដែលបានធ្វើទុកមកផ្សេងៗគ្នា ហេតុដូច្នេះ គប្បីធ្វើអំពើជាកុសលដែលល្អមឲ្យយើងទទួលសេចក្ដីសុខជាផលបាន ។ ឯសង្ខារគឺរាងកាយដែលកើតអំពីគ្រឿងផ្សំនឹងគេចរត់ឲ្យផុតអំពីសភាវធម៌ គឺចាស់គ្រាំគ្រាទ្រុឌទ្រោម និងការបែកធ្លាយស្លាប់បាត់ទៅវិញមិនបាន ។ ហេតុនេះជនទាំងឡាយដែលបានកើតមកជាមនុស្សប្រុស-ស្រីហើយនេះ ត្រូវដឹងខ្លួនឲ្យច្បាស់ថាដែលវិលកើតវិលស្លាប់ក្នុងសង្សារវដ្ដនេះ តែងចួបនឹង

សេចក្តីទុក្ខខ្លះ ចួបនឹងសេចក្តីសុខខ្លះ ជាធម្មតា ។ តែសេចក្តីសំខាន់ដែលត្រូវគិតជានិច្ចក្នុងខ្លួននោះគឺ ៖

" **កុំបណ្តោយចិត្តឲ្យរីករាយ ឬឲ្យសៅហ្មងហួសហេតុ** "។ ប៉ុណ្ណោះក៏សមគួរដល់ឋានៈរបស់ខ្លួនយើង ដែលជាអ្នកចង់បានសេចក្តីសុខ ។ សត្វលោកទាំងអស់, សព្វថ្ងៃនេះ តណ្ហាកំពុងដុតឲ្យក្តៅរោលរាល, ជរាកំពុងជញ្ជក់ស៊ីឲ្យគ្រាំគ្រា, មច្ចុរាជកំពុងចាំស្កាត់នៅខាងមុខ ។ គួរប្រញាប់ធ្វើអំពើល្អគឺបុណ្យ ការបំពេញបុណ្យតាមព្រះពុទ្ធសាសនា ក៏គឺការទូន្មានប្រៀនប្រដៅចិត្ត កុំឲ្យលង់លុះទៅក្នុងសេចក្តីអាក្រក់ ធ្វើចិត្តឲ្យស្ថិតនៅក្នុងសេចក្តីល្អឈ្មោះថា ៖ " **ប្រតិបត្តិធម៌** " នេះជាវិធីប្រសើរបំផុត ជាកំពូលលើសសាសនាទាំងឡាយក្នុងលោក ។

ហេតុនេះ **សូមឲ្យអស់លោក-អ្នកទាំងឡាយ តាំងចិត្តព្យាយាមប្រតិបត្តិ ទៅតាមគោលព្រះពុទ្ធសាសនាចុះ គង់នឹងបានសេចក្តីសុខក្សេមក្សាន្តគ្រប់ទិវារាត្រីពុំខាន ៕**

* ចម្លងចប់នៅក្រុងម៉ុងរេអាល, ថ្ងៃ១ ៗ ៦ ឆ្នាំរោង ចត្វាស័ក ព.ស. ២៥៥៦ ត្រូវនឹងថ្ងៃអាទិត្យ ទី ១៣ ខែឧសភា គ.ស. ២០១២

វ៉ាត ភិក្ខុ

# សមាសភាពចូលរួម

១. ឧបាសក មុិញ សាវ៉ាន

២. ឧបាសក ហុិម ឆាន់

៣. លោក វ៉ាត សុគន្ធ

៤. លោក វ៉ាត តារា ( ទីទី )

៥. លោក វ៉ាត ម៉ូលីវណ្ណា

៦. កញ្ញា វ៉ាត វារីយ៉ា



# នាមពុទ្ធបរិស័ទ

## មានសទ្ធាជ្រះថ្លាបានបរិច្ចាគបច្ច័យដើម្បីបោះពុម្ព

## សៀវភៅ " ឧបនីយតិសូត្រ " ជាធម្មទាន

. ឧបាសក **មុំញូ សាវ៉ាន** និងឧបាសិកា **សិម ចាន់ធូរ៉ា**

. ឧបាសក **ហ៊ិម ឆាន់** និងឧបាសិកា **សាមិត សោភ័ណ**

. អ្នកស្រី **សិម ចាន់ទេវី**

. ឧបាសិកា **ជា នាង**

. អ្នកស្រី **សុខ ស៊ីថុល**

. ឧបាសិកា **ជា ស្រីយុទ្ធថូ**

. អ្នកស្រី **យឹម ច័ន្ទឌី**

. លោក **ស្ងួន ច័ន្ទទេហា**

. លោក **ប៊ុនចាន់ ប្រេដ្ធដេរិក**

. លោក **ប៊ុនចាន់ ស្ទីវិន**

. លោក **វ៉ាត តារា**

. លោក **វ៉ាត ម៉ូលីវណ្ណា**

. កញ្ញា **វ៉ាត វារីយ៉ា**

. លោក **វ៉ាត តិរក្ស** និងអ្នកស្រី **មៀច វណ្ណា**

សូមពុទ្ធបរិស័ទដែលបានចូលរួមបោះពុម្ពសៀវភៅនេះ
ជាធម្មទានបានជួបប្រសព្វតែនឹងសន្តិភាព សុខដុមរមនា សុភមង្គល
បានសម្រេចនូវសម្មាទិដ្ឋិគ្រប់ៗជាតិ និងបានឧបនិស្ស័យរួចចាកផុត
ទុក្ខទាំងពួងកុំបីឃ្លៀងឃ្លាតឡើយ !

**សូមអនុមោទនា** !



# ជូនពរព្រះពុទ្ធសាសនា



សូមឲ្យព្រះពុទ្ធសាសនារុងរឿងចំរើន

សូមឲ្យព្រះពុទ្ធសាសនាផ្សាយទូទៅពេញពិភពលោក

សូមឲ្យលោកទាំងមូលបានប្រកបដោយសន្តិភាព

ព្រះសក្យមុនីសម្ពុទ្ធទ្រង់ត្រាស់ថា **នត្ថិ សន្តិ បរំ សុខំ**

ពុំមានសេចក្តីសុខដទៃក្រៅពីសេចក្តីស្ងប់ឡើយ ។



## ព្រះតេជព្រះគុណ ប៉ាង ខាត់ វីរិយបណ្ឌិតោ

សាស្ត្រាចារ្យពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុ និងនៅ

សាកលវិទ្យាល័យអក្សរសាស្ត្រ ភ្នំពេញ

**"វត្តឧណ្ណាលោម"**

* ចម្លងតាមច្បាប់ដើមដោយខ្ញុំព្រះករុណា ខ្ញុំបាទ វ៉ាត ភិរក្ស

**សម្រាប់ចែកជាធម្មទាន**